**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.[illegible]

## ប្រកាស

## ស្តីពី

## បែបបទ និងនីតិវិធីចំណាយលើការជួសជុលអន្តរាគមន៍បន្ទាន់ផ្លូវថ្នល់ ស្ពាន និងលូ ក្រោមអាណាប័កក្រសួងសាធារណការ និងដឹកជញ្ជូន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទាន សម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់ការងារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.



ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ត្រូវបានបម្រុងឥណទានថវិកាមិនលើសពី ២០% (ម្ភៃភាគរយ) នៃឥណទានថវិកាសម្រាប់ការងារជួសជុលនិងថែទាំផ្លូវថ្នល់ (ជំពូក៦១ គណនី៦០១៥ អនុគណនី៦១០៥៣) ដែលបានគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន សម្រាប់ត្រៀមប្រើប្រាស់អន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ ស្ពាន និងលូទាំងឡាយណាដែលកំពុងចរាចរ ឬដំណើរការ ហើយត្រូវបានកាត់ផ្តាច់ ឬរកកល់នឹងដាច់ដោយប្រការណាមួយ ឱ្យដំណើរការជាប្រក្រតីឡើងវិញ។

**ប្រការ២.-**

ថវិកានេះ នឹងត្រូវផ្តល់ជូនដល់អង្គភាពជំនាញក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន តាមរបៀប ដូចខាងក្រោម÷

- នៅរៀងរាល់ដើមឆ្នាំ ក្រោយពីទទួលបានសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ថវិកាមិនលើសពីចំនួន ៣០% (សាមសិបភាគរយ) នៃឥណទានថវិកាបម្រុងសម្រាប់ការងារអន្តរាគមន៍ជួសជុលបន្ទាន់ នឹងត្រូវផ្តល់ជូនតាមរយៈបុរេប្រទានថវិកា។
- ការបើកផ្តល់បន្ទាប់មកទៀត នឹងត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញឡើងវិញនូវថវិកាដែលបានចំណាយ រហូតដល់អស់កញ្ចប់ឥណទានថវិកាបម្រុងប្រចាំឆ្នាំ។
- ដើម្បីសម្រួលដល់ការបំពេញថវិកាឡើងវិញឱ្យមានប្រសិទ្ធភាពខ្ពស់ របាយការណ៍ចំណាយ និងរបាយការណ៍អនុវត្តការងារ ត្រូវផ្តល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុភ្លាម ក្រោយពេលមុខចំណាយនីមួយៗត្រូវបានអនុវត្តចប់សព្វគ្រប់។ ក្នុងករណីមានភាពមិនច្បាស់លាស់ណាមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចស្នើសុំឱ្យមានការបំភ្លឺបន្ថែម ឬចុះពិនិត្យដល់ការដ្ឋាន មុននឹងផ្តល់ថវិកាបំពេញឡើងវិញ។

នៅរៀងរាល់ដើមឆ្នាំ ផែនការចំណាយប្រចាំត្រីមាស ត្រូវរៀបចំឡើងផ្អែកតាមតម្រូវការចាំបាច់ ឬ/និង ទំហំនៃការខូចខាតជាក់ស្តែង ដើម្បីធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃចំណាយឥណទានថវិកាបម្រុងសម្រាប់ការងារអន្តរាគមន៍ជួសជុលបន្ទាន់។ ផែនការចំណាយនេះ ត្រូវដាក់ស្នើសុំការសម្រេចពីគណៈកម្មការអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ៣.-**

អង្គភាពជំនាញក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន រួមមាន នាយកដ្ឋានជំនាញ និងមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តការងារអន្តរាគមន៍ជួសជុលបន្ទាន់នេះ តាមនីតិវិធីដែលអនុវត្តដោយអង្គភាពរដ្ឋ។ ហាមដាច់ខាតប្រគល់សិទ្ធិឱ្យក្រុមហ៊ុនឯកជនមៅការអនុវត្ត។

**ប្រការ៤ .-**

ទឹកប្រាក់អតិបរមាចំនួន ២០០ លានរៀល (ពីររយលានរៀល) នឹងត្រូវអនុញ្ញាតចំពោះមុខសញ្ញាចំណាយនីមួយៗ។ ក្នុងករណីដែលមានតម្រូវការចំណាយថវិកាច្រើនជាងនេះ ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវស្នើសុំការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

**ប្រការ៥ .-**

ក្នុងករណីដែលពិនិត្យឃើញថា រហូតដល់ដំណាច់ឆ្នាំ ថវិកាមិនអាចអនុវត្តចំណាយអស់ ឥណទានថវិកាដែលនៅសល់អាចបង្វែរទៅប្រើប្រាស់សម្រាប់ការងារជួសជុលនិងថែទាំផ្លូវថ្នល់ ឬស្ពានទាំងឡាយណាដែលកំពុងមានតម្រូវការបន្ទាន់ ឬចាំបាច់ ដោយត្រូវស្នើសុំការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

សាច់ប្រាក់ដែលបានបើកផ្តល់ជាបន្តបន្ទាប់ក្នុងឆ្នាំ ហើយនៅសល់មិនបានចំណាយ នឹងត្រូវបង្វែរបង់ចូលថវិការដ្ឋវិញនាដំណាច់ឆ្នាំ តាមរូបភាពជាសំណេះចំណាយ។

**ប្រការ៧ .-**

ថវិកាមិនលើសពីចំនួន ៣០% (ដូចចែងក្នុង **ប្រការ២**) សម្រាប់ឆ្នាំបន្ទាប់ នឹងត្រូវផ្តល់ជូនក្រសួងសាធារណការនិងដឹកជញ្ជូន ក្រោយពីរបាយការណ៍ទូទាត់ចំណាយក្នុងឆ្នាំកន្លងទៅ និងរបាយការណ៍ស្តីពីការបង់សំណេះចំណាយចូលថវិកាជាតិទាំងអស់ ត្រូវបានផ្តល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៨ .-**

កម្មវត្ថុចំណាយដូចមានចែងក្នុង **ប្រការ១** ខាងលើ មិនគ្របដណ្តប់លើការខូចខាតទាំងឡាយណាដែលបណ្តាលមកពីបទល្មើសនៃការដឹកជញ្ជូនលើសទម្ងន់កំណត់ និងបទល្មើសបំផ្លិចបំផ្លាញសម្បត្តិផ្លូវថ្នល់ផ្សេងទៀតនោះទេ ដែលការងារនេះត្រូវស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់សមត្ថកិច្ចពាក់ព័ន្ធនានាក្នុងការទប់ស្កាត់ និងចាប់ឱ្យជនប្រព្រឹត្តបទល្មើសទទួលខុសត្រូវ ចំពោះមុខច្បាប់ និងសងនូវការខូចខាត។

**ប្រការ៩ .-**

ហាមដាច់ខាតចំពោះការប្រើប្រាស់កញ្ចប់ថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ខុសពីគោលដៅ ដូចមានចែងក្នុង **ប្រការ១** ខាងលើ រាប់ទាំងការចំណាយលើប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រាក់ឧបត្ថម្ភផ្សេងៗ ឬប្រាក់បេសកកម្មរបស់មន្ត្រីរាជការ។

**ប្រការ១០ .-**

ចំណាយថវិកាសម្រាប់ការងារអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ ស្ពាន និងលូ ត្រូវស្ថិតក្រោមកម្មវត្ថុនៃការត្រួតពិនិត្យ អធិការកិច្ច និងសវនកម្មតាមក្រោយ។ ដើម្បីសម្រួលដល់ការងារនេះ សក្ខីប័ត្រចំណាយត្រូវរក្សាទុកនៅអង្គភាពអនុវត្តចំណាយផ្ទាល់ ហើយរបាយការណ៍ចំណាយត្រូវច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការខូចខាតផងដែរ។

**ប្រការ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ និងប្រកាសលេខ ៥៤៦ សហវ.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ និងប្រកាសលេខ ១០២៤ សហវ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ព្រមទាំងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ